អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៨

# សេចក្តីប្រកាសព័ត៌មាន
# អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា ជនជាប់ចោទ នួន ជា និង ខៀវ សំផន មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្រពីររូបឱ្យពិនិត្យវាយតម្លៃជនជាប់ចោទ នួន ជា និង ខៀវ សំផន ដើម្បីកំណត់ថាតើពួកគាត់នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការក្នុងសំណុំរឿង ០០២/០២ ដែរ ឬ ទេ។

អ្នកជំនាញបានធ្វើការពិនិត្យ នួន ជា និង ខៀវ សំផន នៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៨។ បន្ទាប់ពីបានពិនិត្យរបាយការណ៍វេជ្ជសាស្ត្ររួច អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដោយបញ្ជាក់ថា ជនជាប់ចោទទាំងពីរនៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងពុំមានការចុះខ្សោយផ្នែកបញ្ញា ស្មារតី ឬ រាងកាយដែលរារាំងមិនឱ្យពួកគាត់បន្តចូលរួមដំណើរការសវនាការនៃសំណុំរឿង ០០២/០២ នេះ ឡើយ។

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់លើអនុសាសន៍របស់អ្នកជំនាញ ដែលណែនាំឱ្យមានការត្រួតពិនិត្យជាទៀងទាត់លើមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទ។

សេចក្តីសម្រេចទាំងស្រុងរបស់អង្គជំនុំជម្រះសាលាដំបូងលើសម្បទារបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន ក្នុងការចូលរួមសវនាការ អាចរកបានតាមរយៈតំណខាងក្រោមនេះ៖

https://eccc.gov.kh/km/document/court/secktiismrecloekdiipraammuaystiibii-smpdaarps-jn-jaap-cood-nuan-jaa-knungkaar

https://eccc.gov.kh/km/document/court/secktiismrecloekdiipraammuaystiibii-smpdaarps-jn-jaap-cood-khiev-smphn-knungkaar

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*


លោក **នេត្រ ភក្ត្រា**
ប្រធានស្ដីទីផ្នែកកិច្ចការសាធារណៈ និង
ជាមន្ត្រីនាំពាក្យនៃសាលាក្ដីខ្មែរក្រហម
ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៨១៥៦
អ៊ីមែល៖ abusaleh@un.org

លោកស្រី **ហាយ៉ាត់ អាបូសាឡេស**
មន្ត្រីផ្នែកកិច្ចការសាធារណៈ
ទូរសព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ៩៣៦
អ៊ីមែល៖ abusaleh@un.org